# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ១០:៣០ ព្រឹក នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានប្រារព្ធកិច្ចប្រជុំទ្វេភាគីរវាងរដ្ឋបាលគយកម្ពុជា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា និងសមភាគីរដ្ឋបាលគយជប៉ុន ដឹកនាំដោយលោក **អាគ់ស៊ីអុ ស៊ីមូតា** អគ្គនាយករដ្ឋបាលគយជប៉ុន ក្នុងគោលបំណងពិភាក្សាគ្នាលើកិច្ចសហប្រតិបត្តិការលើវិស័យគយជាពិសេសកិច្ចសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។

នៅក្នុងកិច្ចប្រជុំនេះបន្ទាប់ពីភាគីគយកម្ពុជាបានលើកឡើងជាសង្ខេបអំពីវឌ្ឍនភាព និងសមិទ្ធិផលសម្រេចបានពេលថ្មីៗរបស់អង្គភាពខ្លួនមក ភាគីគយជប៉ុនក៏បានថ្លែងអំណរគុណចំពោះការស្វាគមន៍ និងបានសង្កត់ធ្ងន់ពីភាពចាំបាច់កាន់តែខ្លាំងនូវការពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសជប៉ុនជាមួយកម្ពុជា ក៏ដូចជាអាស៊ាន ព្រមទាំងបណ្តាប្រទេសដទៃទៀតលើពិភពលោក ក្នុងការធានាឡើងវិញនូវសន្តិសុខ និងភាពរលូននៃខ្សែចង្វាក់ផ្គត់ផ្គង់ផលិតកម្ម បន្ទាប់ពីផលវិបាកនៃគ្រោះធម្មជាតិរញ្ជួយផែនដី រលកស៊ូណាមី និងវិបត្តិថាមពលនុយក្លេអ៊ែរនៅជប៉ុននាខែកន្លងទៅ ។ ដោយយល់ថាទោះបីជាមានវិបត្តិគ្រោះធម្មជាតិនេះ ក៏ទំហំពាណិជ្ជកម្មផ្លាស់ប្តូរទំនិញរវាងប្រទេសទាំងពីរនៅតែមានស្ថេរភាពជាធម្មតា ហើយកាន់តែកើនឡើងជាលំដាប់ពីថ្ងៃទៅមួយថ្ងៃនោះ ភាគីទាំងពីរបានពិភាក្សាគ្នាលើវិស័យគយជាអាទិភាពនៃការពង្រីកកិច្ចសហប្រតិបត្តិការគ្នារវាងប្រទេសទាំងពីរ និងបានព្រមព្រៀងគ្នាដូចតទៅ ÷

១. ប្រទេសជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងសហការគ្នាជួយកម្ពុជា ក្នុងការចូលជាសមាជិកអនុសញ្ញាក្រុងក្យូតូកែសម្រួល (Revised Kyoto Convention) ។

២. រដ្ឋបាលគយជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) នឹងបន្តផ្តល់ជំនួយបច្ចេកទេសលើផ្នែកគ្រប់គ្រងហានិភ័យ ការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចដែលទទួលសិទ្ធិ (Authorized Economic Operator - AEO) ការកំណត់តម្លៃគិតពន្ធគយ និងការធ្វើចំណាត់ថ្នាក់ទំនិញ ។

៣. អង្គការគយពិភពលោក (WCO) និង ADB នឹងរៀបចំការសិក្សាពីរយៈពេលនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ (Time Release Study - TRS) នៅក្នុងបណ្តាប្រទេសអាស៊ាន រួមទាំងប្រទេសកម្ពុជាផងដែរ នៅឆ្នាំ ២០១២ និង ឆ្នាំ ២០១៥ ខាងមុខនេះ ។

៤. ប្រទេសជប៉ុន នឹងពង្រីកការផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតផ្នែកកម្មសិទ្ធិបញ្ញា តាមរយៈ WCO ដល់មន្ត្រីគយនិងរដ្ឋាករកម្ពុជា ទៅសិក្សានៅសាកលវិទ្យាល័យនៃប្រទេសជប៉ុនចាប់ពីឆ្នាំ ២០១១ នេះតទៅ ។

កិច្ចប្រជុំទ្វេភាគីនេះ បានបញ្ចប់នាម៉ោង ១២:០០ នាទីព្រឹក ថ្ងៃដដែល ក្រោមបរិយាកាសមិត្តភាពរីករាយ និងស្និទ្ធស្នាលក្រៃលែង ។

រាជធានីភ្នំពេញថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១